# ការពិនិត្យឡើងវិញលើការបកប្រែកំណត់ហេតុនៃការស្តាប់ចម្លើយសាក្សីក្នុងសំណុំរឿង០០២

ឯកសារដើម
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/date de reception):
22 / 02 / 2011
ម៉ោង (Time/Heure) : 10 : 50
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA

រៀបចំដោយអង្គភាពបកប្រែភាសា
ថ្ងៃទី២៦ ខែមករា ឆ្នាំ២០១១

## សេចក្តីផ្តើម

នៅថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១០ អង្គបុរេជំនុំជម្រះនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បានចេញសេចក្តីសម្រេចរបស់ខ្លួន លើសេចក្តីជូនដំណឹងរបស់មេធាវីការពារក្តីអំពីកំហុសក្នុងការបកប្រែ[1]។ សេចក្តីសម្រេចនេះបានណែនាំឱ្យអង្គភាពបកប្រែភាសា ("ITU") ពិនិត្យឡើងវិញលើការបកប្រែកំណត់ហេតុនៃការស្តាប់ចម្លើយសាក្សីចំនួន ១០% ជាភាសាអង់គ្លេស និងជាភាសាបារាំង ដែលឯកសារដើមជាភាសាខ្មែរនៅក្នុងសំណុំរឿង០០២។ អង្គបុរេជំនុំជម្រះក៏បានបង្គាប់ឱ្យដាក់សំណើសុំកែតម្រូវកំហុសក្នុងការបកប្រែ ទៅផ្នែកគ្រប់គ្រងតុលាការ និងរាយការណ៍អំពីលទ្ធផលនៃការពិនិត្យឡើងវិញលើចម្លើយសាក្សីទាំងចំនួន ១០% នេះ ជូនអង្គបុរេជំនុំជម្រះ។

របាយការណ៍នេះរៀបរាប់អំពីការចងក្រងកំណត់ហេតុនៃការស្តាប់ចម្លើយសាក្សីដែលមាននៅក្នុងសំណុំរឿង០០២ វិធីសាស្ត្រដែលបានប្រើក្នុងការស្វែងរកនូវភាពមិនស្របគ្នា រវាងការបកប្រែភាសាបារាំង និងភាសាអង់គ្លេស និងលទ្ធផលនៃការពិនិត្យកំណត់ហេតុនៃការស្តាប់ចម្លើយសាក្សីឡើងវិញចំនួន ១០% នៃកំណត់ហេតុនៃការស្តាប់ចម្លើយសាក្សីទាំងអស់។ សម្រាប់ការពិចារណាបន្ថែមទៀត ITU ក៏បានផ្តល់សេចក្តីសង្ខេបអំពីប្រភេទនៃភាពមិនស្របគ្នា ដែលទំនងជាកើតមានរវាងការបកប្រែនៅក្នុងឧបសម្ពន្ធនៃសេចក្តីរាយការណ៍នេះ។

## I. ការចងក្រងកំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី

[1] សេចក្តីសម្រេចលើសេចក្តីជូនដំណឹងរបស់មេធាវីការពារក្តីអំពីកំហុសក្នុងការបកប្រែ ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១០ ឯកសារ T10147, ERN 00629421 – 00629425 ០០២/២០-១០-២០១០-អវតក/អបជ(១៤)។

យោងតាមតួលេខដែលទទួលបានពីអង្គភាពបណ្ណសារ សំណុំរឿង០០២ នាពេលបច្ចុប្បន្ននេះ មានកំណត់ហេតុនៃការស្តាប់ចម្លើយសាក្សីចំនួន ៧៦៧។ កំណត់ហេតុទាំងនេះ មានចំនួនសរុបប្រហែល ៥.១០០ ទំព័រ។ ភាគច្រើនបំផុតនៃកំណត់ហេតុទាំងនេះត្រូវបានសរសេរជាភាសាខ្មែរ។ ទោះបីជាយ៉ាងណាក៏ដោយ ក៏មានកំណត់ហេតុមួយចំនួនដែលភាសាដើមត្រូវបានសរសេរជាភាសាមួយ ក្នុងចំណោមភាសាជាផ្លូវការពីរផ្សេងទៀតរបស់ អ.វ.ត.ក។ ឧទាហរណ៍ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សីមួយដែលភាសាដើមត្រូវបានសរសេរជាភាសាបារាំង ត្រូវបានកត់សម្គាល់ក្នុងចំណោមកំណត់ហេតុនៃការស្តាប់ចម្លើយសាក្សីដែលត្រូវបានយកមកពិនិត្យឡើងវិញចំនួន១០% នេះ[2]។

ការស្តាប់ចម្លើយសាក្សីជនជាតិខ្មែរត្រូវបានធ្វើឡើងជាភាសាខ្មែរ។ ការស្តាប់ចម្លើយទាំងនេះក៏អាចត្រូវបានធ្វើឡើងដំណាលគ្នាជាភាសាបារាំង ឬភាសាអង់គ្លេសផងដែរ ប្រសិនបើមានវត្តមានអ្នកស៊ើបអង្កេតអន្តរជាតិ។ ជារឿយៗ អ្នកស៊ើបអង្កេតស្តាប់ចម្លើយសាក្សី ដោយមានជំនួយពីអ្នកបកប្រែ ទោះបីជាមិនមែនជាលក្ខណៈប្រព័ន្ធក៏ដោយ។ ដូច្នេះ សំណួរ និងចម្លើយត្រូវបានបកប្រែពីភាសាខ្មែរទៅជាភាសាអង់គ្លេស ឬភាសាបារាំង និងពីភាសាអង់គ្លេស ឬពីភាសាបារាំងទៅជាភាសាខ្មែរ។

កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សីដែលធ្វើឡើងជាភាសាខ្មែរ បន្ទាប់មកត្រូវបកប្រែទៅជាភាសាអង់គ្លេស និងភាសាបារាំង។ ការស្តាប់ចម្លើយត្រូវបានធ្វើឡើងជាប់ជាប្រចាំក្នុងអំឡុងពេលបំពេញកិច្ចស៊ើបសួរលើសំណុំរឿង០០២។ យោងទៅលើសមត្ថភាពធនធានដែលមាននៅនឹងកន្លែង ក្នុងអំឡុងពេលនេះ ITU ត្រូវបានស្នើឱ្យផ្តល់ការបកប្រែប្រតិចារឹកភាសាដើមខ្មែរ ក្នុងរយៈពេល ២ សប្តាហ៍។ ការបកប្រែទៅជាភាសាទីបី នឹងធ្វើឡើងឆាប់ៗតាមដែលអាចធ្វើបាន។ ដូច្នេះ កាលបរិច្ឆេទនៃការបកប្រែ និងការដាក់ឯកសារអាចនឹងខុសៗគ្នា។ កាលបរិច្ឆេទទាំងនេះ ត្រូវបានបង្ហាញក្នុងកំណត់ហេតុដែលបានពិនិត្យឡើងវិញទាំង ១០%។ អនុលោមតាម បទដ្ឋាននីតិវិធីប្រតិបត្តិជាធរមាននៅពេលនោះ ការពិនិត្យកែតម្រូវពេញលេញមិនមានជានិច្ចកាលឡើយ ទោះបីជាមានយន្តការត្រួតពិនិត្យគុណភាពលើភាសាពីរ នៅគ្រប់ពេលយ៉ាងណាក៏ដោយ។

---

[2] ឯកសារ D108/16 កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី Francois Bizot របស់សហចៅក្រមស៊ើបអង្កេត ថ្ងៃទី២២ ខែមករា ឆ្នាំ២០០៨។

00645831

## II. វិធីសាស្ត្រនៃការពិនិត្យកំណត់ហេតុចំនួន ១០% ឡើងវិញ

កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សីនីមួយៗ ក្នុងចំណោមកំណត់ហេតុនៃការស្តាប់ចម្លើយសាក្សីប្រហែល ៧៦៧ ត្រូវបានកំណត់អត្តសញ្ញាណដោយដីកាចាត់ឱ្យស៊ើបសួរជំនួស និងត្រូវបានយោងដោយលេខឯកសារ។ មានដីកាចាត់ឱ្យស៊ើបសួរជំនួស ចំនួន ៣២ ដែលមានទំហំខុសៗគ្នាសម្រាប់កំណត់ហេតុនៃការស្តាប់ចម្លើយទាំងអស់នេះ។ ដើម្បីជ្រើសរើសយកចំនួនដែលជាតំណាងឱ្យបានត្រឹមត្រូវ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ដែលត្រូវពិនិត្យឡើងវិញ ត្រូវបានជ្រើសយកតាមសមាមាត្រចេញពីកំណត់ហេតុធំៗ នៃប្រភេទដីកាចាត់ឱ្យស៊ើបសួរជំនួស[3]។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សីនីមួយៗ ត្រូវបានជ្រើសយកដោយចៃដន្យចេញពីក្រុមនីមួយៗ ដើម្បីធ្វើជាតំណាង។

ការពិនិត្យចំនួន ១០% ឡើងវិញ មានកំណត់ហេតុនៃការស្តាប់ចម្លើយសាក្សីចំនួន ៧៨ ដែលមានចំនួនសរុប ៥១៤ ទំព័រ។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សីទាំងអស់ លើកលែងតែកំណត់ហេតុនៃការស្តាប់ចម្លើយសាក្សីមួយប៉ុណ្ណោះ ត្រូវបានធ្វើឡើងជាភាសាដើមខ្មែរ និងត្រូវបានបកប្រែ និងដាក់ក្នុងសំណុំរឿងចាប់ពីឆ្នាំ២០០៨ ដល់ឆ្នាំ២០១០។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សីទាំងអស់នៃការពិនិត្យចំនួន ១០% ឡើងវិញ ត្រូវបានដកស្រង់នៅក្នុងដីកាដំណោះស្រាយក្នុងសំណុំរឿង០០២។

ការពិនិត្យឡើងវិញត្រូវបានធ្វើឡើងដោយក្រុមអ្នកបកប្រែផ្ទាល់មាត់ និងអ្នកបកប្រែឯកសាររបស់ ITU ដោយរួមបញ្ចូលទាំងអ្នកដែលប្រើប្រាស់ភាសាអង់គ្លេស ភាសាបារាំង ឬភាសាខ្មែរ។ ការពិនិត្យបឋមលើកំណត់ហេតុទាំង៧៨ ឡើងវិញ ត្រូវបានបញ្ចប់ក្នុងរយៈពេលបីសប្តាហ៍។

ដើម្បីកំណត់ថាតើកំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឆ្លុះបញ្ចាំងត្រឹមត្រូវទៅនឹងសំណៅដើម ឬយ៉ាងណានោះ ការវាយតម្លៃលើការបកប្រែ ត្រូវបានបែងចែកជាពីរដំណាក់កាល ៖ ១) ការពិនិត្យផ្ទៀងផ្ទាត់រកមើលភាពខុសគ្នា*ណាមួយ*រវាងឯកសារជាភាសាអង់គ្លេស និងឯកសារជាភាសាបារាំង

[3] តំណាង ១០% មានកំណត់ហេតុនៃស្តាប់ចម្លើយសាក្សី ដែលស្ថិតនៅក្រោមដីកាចាត់ឱ្យស៊ើបសួរជំនួសដូចខាងក្រោម៖ D108: 9%, D125: 23% , D166: 20%, D232: 10%, D233: 1%, D234: 3%, D25: 5%, D280: 3%, D369: 5%, D40: 3%, D91: 3%។

២) ការពិនិត្យផ្ទៀងផ្ទាត់លើភាពខុសគ្នាដែលត្រូវបានសន្មត ជាមួយនឹងសំណៅជាភាសាខ្មែរដើម្បីសម្រេចចុងក្រោយអំពីន័យដូចគ្នានៃការបកប្រែ។

ក្នុងដំណាក់កាលទីមួយ អ្នកបកប្រែផ្ទាល់មាត់និងអ្នកបកប្រែឯកសារភាសាបារាំង-អង់គ្លេស បានពិនិត្យរកមើលភាពខុសគ្នាទាំងអស់ដែលជាការបកប្រែខុស ការបកបាត់ខ្លឹមសារ និងការបន្ថែមសេចក្តី ជាពិសេស ប្រសិនបើកំហុសបែបនេះទាក់ទិននឹងការរៀបរាប់អំពីពេលវេលា ទីកន្លែង កាលបរិច្ឆេទ ចម្ងាយ អាយុ និងនាមអសាធារណៈ។ បញ្ហាវេយ្យាករណ៍ ការប្រើប្រាស់កាល និងវាក្យសម្ពន្ធត្រូវបានលើកឡើង ប្រសិនបើកំហុសទាំងនោះប៉ះពាល់ ឬទំនងជាប៉ះពាល់ដល់អត្ថន័យ។

ក្នុងដំណាក់កាលទីពីរ អ្នកបកប្រែឯកសារនិងអ្នកបកប្រែផ្ទាល់មាត់ខ្មែរ ពិនិត្យផ្ទៀងផ្ទាត់ចំណុចខុសគ្នាដែលមានគូសសញ្ញាសម្គាល់ ជាមួយកំណត់ហេតុដើម។ ការបកប្រែទាំងអស់ដែលត្រូវបានយល់ថាមិនស្របគ្នាជាមួយនឹងសំណៅដើមភាសាខ្មែរ ត្រូវស្នើសុំធ្វើការកែតម្រូវទៅ ផ្នែកគ្រប់គ្រងគុណភាព។

## III. **លទ្ធផលនៃការពិនិត្យឡើងវិញចំនួន ១០%**

ការពិនិត្យកំណត់ហេតុនៃការស្តាប់ចម្លើយសាក្សីឡើងវិញចំនួន ៧៨ បង្ហាញថា ឯកសារចំនួន ៤៧ មានភាពមិនស្របគ្នា។

### *i. ការបកប្រែបានត្រឹមត្រូវសមតាមគោលបំណង*

ក្នុងចំណោមកំណត់ហេតុនៃការស្តាប់ចម្លើយសាក្សីចំនួន ៧៨ ក្រុម ITU បានរកឃើញឯកសារចំនួន ៣១ ឯកសារ ដែលពុំចាំបាច់មានចំណាត់ការបន្ថែមអ្វីទៀតឡើយ។ ភាគច្រើនបំផុតនៃការបកប្រែទាំងនេះ ត្រូវបានធ្វើឡើងក្នុងឆ្នាំ២០០៩-២០១០។ ភាពមិនស្របគ្នាដែលត្រូវបានកត់សម្គាល់រវាងឯកសារនៅក្នុងក្រុមនេះ ទាក់ទិនទៅនឹងការតម្រឹមអត្ថបទ ទ្រង់ទ្រាយ ការវាយអក្សរបោះពុម្ព ការសរសេរអក្សរទាញសួរ ការប្រើប្រាស់ទម្រង់បែបបទដែលមានស្រាប់ និងជួនកាល វាក្យសព្ទ[4]។

---

[4] ឧទាហរណ៍នៃការដែលនាំឱ្យមានការប្រើប្រាស់វាក្យសព្ទមិនស៊ីគ្នា ដូចជាការប្រើពាក្យ *sandal* សម្រាប់ស្បែកជើង (*sbek cheung*) ឯកសារ D40/13 ERN 00223541 និងពាក្យ *chaussure* សម្រាប់ស្បែកជើង (*sbek cheung*) ឯកសារ D40/13 ERN 00491154 ឬពាក្យ *chief* សំដៅលើ មេ (ប្រធាន) ឯកសារ D125/54 ERN 00274158 និងពាក្យ *maire*

ភាពខុសគ្នាក្នុងទម្រង់បែបនេះ មិនត្រូវបានចាត់ទុកថាធ្វើឱ្យប៉ះពាល់ភាពត្រឹមត្រូវនៃខ្លឹមសារឡើយ។ ទោះបីជាគេអាចស្នើឱ្យមានការកែទម្រង់ជាថ្មីឱ្យមានលក្ខណៈកាន់តែល្អប្រសើរ ឱ្យដូចជាអត្ថបទសរសេរទូទៅក៏ដោយ ការបកប្រែទាំងនេះត្រូវបានចាត់ទុកថា ត្រឹមត្រូវសម្រាប់គោលបំណងបានហើយ។ ការបកប្រែប្រភេទនេះមាន ៤០% នៃការពិនិត្យកំណត់ហេតុឡើងវិញ។

ii. *ការបកប្រែដែលតម្រូវឱ្យមានការពិនិត្យឡើងវិញ*

ការពិនិត្យឡើងវិញចំនួន ១០% បានបង្ហាញថា កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សីចំនួន ៤៧ ក្នុងចំណោមកំណត់ហេតុនៃការស្តាប់ចម្លើយសាក្សីតំណាងទាំងអស់ មានភាពមិនស្របគ្នា ដែលតម្រូវឱ្យមានការពិនិត្យឡើងវិញ។

ការកំណត់លក្ខណៈទូទៅអំពីថាតើហេតុអ្វីបានជាឯកសារបែបនោះ តម្រូវឱ្យមានការពិនិត្យឡើងវិញ ៖

១) ការពុំមានភាពស្មើគ្នាផ្នែកវេយ្យាករណ៍ដែលនាំឱ្យមានភាពមិនច្បាស់លាស់ទៅលើពេលវេលានៃព្រឹត្តការណ៍កាលពីអតីតកាល។ ការប្រើប្រាស់កាល (tense) ជាពិសេសភាសាបារាំង ការប្រើប្រាស់សព្វនាម *(on)* និងការប្រើប្រាស់វេយ្យាករណ៍អកម្ម (Passive Voice) ក្នុងភាសាអង់គ្លេស តម្រូវឱ្យមានការពិនិត្យជាមួយនឹងភាសាខ្មែរ ដែល*កាល* ត្រូវបានប្រើខុសគ្នា ដើម្បីឱ្យដឹងច្បាស់នូវព្រឹត្តការណ៍ទាក់ទិននឹងពេលវេលា[5]។

២) ការបកបាត់ខ្លឹមសារ ជាពិសេសទាក់ទិននឹងពេលវេលា កាលបរិច្ឆេទ ទីកន្លែង និងមនុស្ស។

---

សំដៅលើ មេ (ប្រធាន) ឯកសារ D125/54 00226154។ ទាំងនេះគឺជាការបកប្រែដែលអាចទទួលយកបានអំពីសាធារណៈនាម ដែលមិនប៉ះពាល់អត្ថន័យ ឡើយ។

[5] ឧទាហរណ៍៖ រាប់រយគ្រួសារបានទៅដល់ទីនោះក្នុងអំឡុងឆ្នាំ១៩៧៨ (*hundreds of families arrived there during 1978)* និង (*en 1978, il y avait à peu près une centaine de familles)* ឯកសារ D232/10, ERNs 00373917 និង 00426159។

៣) បញ្ហាប្រឈមជាក់លាក់ដែលមានចំពោះការបកប្រែឯកសារពីភាសាខ្មែរទៅជាភាសាណាមួយ នៅអឺរុប[6]។

IV. **សេចក្តីសន្និដ្ឋាន**

ដោយពិចារណាទៅលើលទ្ធផលខាងលើ ITU កំពុងតែបន្តដាក់ការកែតម្រូវចំពោះកំណត់ហេតុនៃការស្តាប់ចម្លើយសាក្សីនីមួយៗ ដែលត្រូវបានកត់សម្គាល់ ក្នុងអំឡុងការពិនិត្យឡើងវិញ។ បន្ទាប់ពីពិចារណាទៅលើវិសាលភាពនៃភាពមិនស្របគ្នាដែលត្រូវបានកត់សម្គាល់ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សីខ្លះតម្រូវឱ្យមានការកែសម្រួលបន្តិចបន្តួច ហើយកំណត់ហេតុនៃការស្តាប់ចម្លើយសាក្សីខ្លះទៀត តម្រូវឱ្យបកប្រែទាំងស្រុងឡើងវិញ។ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សីណាមួយដែលត្រូវកែប្រែ ត្រូវតែធ្វើឡើងដោយការដាក់សំណើសុំការកែតម្រូវ។

ដូច្នេះ ITU ស្នើសុំពន្យារពេលដើម្បីដាក់កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សីដែលត្រូវបានកែសម្រួល ដោយសារតែ នៅពេលបច្ចុប្បន្ននេះ ITU កំពុងប្រឈមនឹងការខ្វះធនធានបំពេញការងារទាំងនេះ ក៏ដូចជាការងារផ្សេងៗទៀតដែលនៅចំពោះមុខអង្គភាពបកប្រែភាសាផងដែរ។ ITU នឹងដាក់របាយការណ៍នៃដំណើរការការងារនេះជារៀងរាល់ខែ។

ITU តែងតែបាន និងបន្តដំណើរការ ដូចដែលថ្មីៗនេះត្រូវបានរំលឹកដោយអង្គបុរេជំនុំជម្រះ ដោយផ្អែកលើមូលដ្ឋានថា "ក្នុងករណីដែលបញ្ហានៃបកប្រែត្រូវបានរកឃើញ បញ្ហាទាំងនោះអាចត្រូវបានលើកឡើងទៅតាមករណីនីមួយៗ នៅក្នុងអំឡុងពេលនៃការជំនុំជម្រះ"[7]។

ITU នៅតែស្វាគមន៍ចំពោះអង្គជំនុំជម្រះសាលាដំបូង ដើម្បីពិភាក្សាអំពីវិធីដ៏សមរម្យបំផុតក្នុងការបន្តដំណើរការ ដែលទាក់ទិនទៅនឹង *ក្នុងចំណោមប្រការផ្សេងទៀត* ការបែងចែកសមត្ថភាពបកប្រែរបស់ ITU និងការចាប់ផ្តើមឱ្យបានទាន់ពេលវេលានៃការជំនុំជម្រះក្នុងសំណុំរឿង០០២។

---

[6] សូមមើលឧបសម្ព័ន្ធ ១ នៃរបាយការណ៍នេះ។ សូមមើល ផងដែរ ការបកប្រែប្រដេញនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ឯកសារ E69/1.1។

[7] សាលដីកាលើបណ្តឹងឧបាស្គិហេតុរបស់ ខៀវ សំផន ដែលមានគោលដៅផ្អាកភ្លាមៗ និងជាស្ថាពរនូវនីតិវិធី ដោយមូលហេតុមានការរំលោភលើនីតិវិធី កថាខណ្ឌ ១៦ ថ្ងៃទី១២ ខែមករា ឆ្នាំ២០១១។

00645835

**ឧបសម្ព័ន្ធ ១**

*ខាងក្រោមនេះគឺជាសេចក្ដីសង្ខេបអំពីប្រភេទខ្លះនៃបញ្ហាប្រឈម នៅពេលបកប្រែឯកសារ ឬបកប្រែផ្ទាល់មាត់ពីភាសាណាមួយ និងទៅជាភាសាណាមួយដែលជាភាសាផ្លូវការទាំងបីរបស់ អ.វ.ត.ក។ សេចក្ដីសង្ខេបនេះត្រូវបានធ្វើឡើង នៅក្នុងរបាយការណ៍លើកមុនរបស់ ITU ដែលមានចំណងជើងថា* ការបកប្រែប្រយេញនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ឯកសារ E69/1.1។

*វាក្យសម្ពន្ធ*

វាក្យសម្ពន្ធភាសាខ្មែរ គឺជាបញ្ហាប្រឈមមួយនៅពេលបកប្រែទៅជាភាសាបារាំង ឬភាសាអង់គ្លេស។ លំដាប់លំដោយនៃពាក្យ និងប្រយោគក្នុងភាសាខ្មែរ ខុសគ្នាយ៉ាងខ្លាំងពីភាសារអង់គ្លេស និងភាសាបារាំង។ ជារឿយៗ ប្រយោគភាសាខ្មែរ មិនមានប្រធានច្បាស់លាស់ទេ ដែលគេត្រូវស្វែងយល់ទៅតាមបរិបទនីមួយៗ។

*ពហុវចនៈ/ការឯកភាពក្នុងតួលេខ/ភេទ*

ពហុវចនៈមិនត្រូវបានបង្ហាញក្នុងភាសាខ្មែរទេ វៀរលែងតែអ្នកនិយាយយល់ឃើញថាវាចាំបាច់។ ជារឿយៗ ពហុវចនៈត្រូវគេសំអាងលើបរិបទ ហើយមានករណីជាច្រើន ដោយផ្អែកលើមូលដ្ឋាននៃកំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ដែលអ្នកបកប្រែឯកសារផ្សេងៗត្រូវពិគ្រោះឯកសារ ដើម្បីកំណត់ថាតើគិញ*ម្នាក់* ឬគិញ*ច្រើននាក់*បានបាញ់កាំភ្លើងមួយគ្រាប់ ឬបាញ់កាំភ្លើងច្រើនគ្រាប់ទៅលើមេឃ ឬក៏ថាតើ មនុស្ស*ម្នាក់*ឬ*ច្រើននាក់*ត្រូវបានចាត់តាំងឲ្យតាមដានឃ្លាំមើលអង្គភាពមួយ។

ចំពោះបញ្ហាភេទវិញ ការនិយាយសំដៅទៅរកបងប្អូនគឺជាបញ្ហាដ៏ស្មុគស្មាញ ហើយអ្វីដែលជាបញ្ហានោះគឺទាក់ទងនឹងអាយុ មិនមែនភេទនោះទេ។ ដូច្នេះ ពេលនិយាយអំពីបងប្អូន សាក្សីជនជាតិខ្មែរអាចប្រើពាក្យ "បង" ឬ "ប្អូន" តែមិនបញ្ជាក់អំពីភេទទេ ចំណែកឯសាក្សីជនជាតិបរទេសជាធម្មតាបង្ហាញ អំពីភេទ (បងប្អូនប្រុស ឬបងប្អូនស្រី) ប៉ុន្តែគ្មានសញ្ញាណាមួយបញ្ជាក់អំពីអាយុនោះទេ ហើយចាត់ទុកអាយុថាជាបញ្ហាមិនពាក់ព័ន្ធទេ។

*ការបង្ហាញអំពីឋានានុក្រមសង្គម*

ភាសាអង់គ្លេស និងភាសាបារាំងហៅអ្នកណាម្នាក់ ដោយគ្រាន់តែប្រើពាក្យ Mr., Mrs., Miss ឬ Ms. ប៉ុណ្ណោះ ចំណែកភាសាខ្មែរមានរបៀបច្រើនយ៉ាងក្នុងការហៅអ្នកណាម្នាក់ រួមទាំងការហៅដោយសំដៅទៅលើមុខរបរវិជ្ជាជីវៈពាក់ព័ន្ធរបស់បុគ្គលនោះ ដូចជា *គ្រូ* ("គ្រូបង្រៀន" ដូចជា *គ្រូ* សុនសេន) *អាចារ្យ* ("គ្រូបង្រៀន" "មនុស្សដែលមានវិជ្ជាជ្រៅជ្រះ") ឬ *ជាង* ("អ្នកបច្ចេកទេស")។ ឧទាហរណ៍ ជាធម្មតា ប្រជាជនខ្មែរនិយាយសំដៅរកជាងដេរ ដោយការហៅជាងនៅពីមុខឈ្មោះ ដូចជា *ជាង* ណារេត។ ភាសាអង់គ្លេស ឬភាសាបារាំងស្តាប់ទៅមិនធម្មតាទេ ពេលគេហៅថា "Tailor Nareth"។ ឧទាហរណ៍មួយទៀត គឺពាក្យ *តា* ដែលមានន័យថា "ជីតា" ប៉ុន្តែត្រូវបានពួកខ្មែរក្រហមប្រើប្រាស់ដើម្បីនិយាយសំដៅ *កម្មាភិបាល* សូម្បីតែកម្មាភិបាលទាំងនោះក្មេងក៏ដោយ។ ដូចជា អ្នកមើលការខុសត្រូវមន្ទីរ ម១៣ និងមន្ទីរ ស២១ ឌុច ត្រូវបានគេហៅថា *តា* ឌុចៗ ទោះបីជាគាត់ទើបតែមានអាយុខ្ទង់សាមសិបឆ្នាំក៏ដោយ។

*កាល*

កាលនៃវេយ្យាករណ៍ត្រូវបានគេបញ្ជាក់ផ្សេងៗគ្នាក្នុងភាសាខ្មែរ។ កាល ត្រូវបានបង្ហាញតាមរយៈវាក្យសម្ពន្ធ និងបរិបទ នៅក្នុងភាសាខ្មែរ។ ចំណែកក្នុងភាសាអង់គ្លេស និងភាសាបារាំងវិញ កាលត្រូវបានបង្ហាញតាមរយៈប្រព័ន្ធកិរិយាសព្ទវេយ្យាករណ៍។ ជាធម្មតា វាមិនច្បាស់ថាតើសាក្សីដែលនិយាយភាសាខ្មែរថា "មិនដឹង" ចង់មានន័យថា គាត់មិនដឹងអំពីពេលវេលា នៃអង្គហេតុកាលនៅពេលនោះ ឬគាត់មិនដឹងពេលឥឡូវនេះ នោះទេ។

*វាក្យសព្ទ*

នៅ អ.វ.ត.ក មានបញ្ហាប្រឈមពីរក្នុងបញ្ហាវាក្យសព្ទគឺ ៖ វាក្យសព្ទរបស់ខ្មែរក្រហម និងវាក្យសព្ទច្បាប់ និងវាក្យសម្ពន្ធ។ មិនមានការបង្រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យនៅក្នុងសាលាទេ។ ដូច្នេះ ប្រជាជនកម្ពុជាក្មេងៗមិនស្គាល់ទម្រង់នៃការនិយាយរបស់ខ្មែរក្រហមទេ។